**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ ៣៦៣៣ ភ.ល

ថ្ងៃ ព្រហ. ៧កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២

## សូមជម្រាបជូន
## លោកប្រធានក្រុមហ៊ុន មាគ៌ា វឌ្ឍនៈ ខនស្ត្រាក់សិន

**កម្មវត្ថុ:** ប្រកាសលុបចោលការដេញថ្លៃស្តីពីការជួសជុល និងលាបថ្នាំអគារក្នុងបរិវេណរោងចក្រផលិតទឹកស្អាតជ្រោយចង្វារ (ផែនការកែតម្រូវ- ឆ្នាំ២០២២)។

**យោង:** កំណត់ហេតុបើកឯកសារដេញថ្លៃ(លើកទី២) កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជម្រាបជូនលោកប្រធានក្រុមហ៊ុនមេត្តាជ្រាបថា៖ យោងតាមស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩ នៅតែមិនថមថយ ជាពិសេសគឺមេរោគបម្លែងថ្មី ប្រភេទអូមីក្រុង ដែលមានអត្រា ចម្លងខ្លាំង អាចប្រឈមជាមួយនឹងការចម្លងដោយថាហេតុ តាមរយៈការចេញ-ចូលរបស់កម្មករដែលធ្វើការងារនៅបរិវេណរោងចក្រផលិតទឹកស្អាតជ្រោយចង្វារនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយមួយវិញទៀត តាមការណែនាំរបស់អាជ្ញាធរសេវនកម្មជាតិបញ្ជាក់ថា រាល់ការអនុវត្តកិច្ចលទ្ធកម្មមិនតម្រូវអោយមានការចុះកិច្ចសន្យាឆ្លងឆ្នាំ ដូចនេះគណៈកម្មាធិការលទ្ធកម្មសូមប្រកាសលុបចោលការដេញថ្លៃស្តីពីការជួសជុល និងលាបថ្នាំអគារក្នុងបរិវេណរោងចក្រផលិតទឹកស្អាតជ្រោយចង្វារ (ផែនការកែតម្រូវ-ឆ្នាំ២០២២)។

ក្រុមហ៊ុនអាចដាក់ពាក្យដកប្រាក់កក់ធានាការដេញថ្លៃពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការចាប់ពីថ្ងៃប្រកាសនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានក្រុមហ៊ុនមេត្តាជ្រាប និងអធ្យាស្រ័យ។

សូមលោកប្រធានក្រុមហ៊ុនទទួលនូវការគោរពរាប់អានពីយើងខ្ញុំ។

**អគ្គនាយក**

**ឡុង ណារ៉ូ**

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្ម
- អង្គភាពលទ្ធកម្ម
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ